# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាពិធីត្រាស់ហៅយ៉ាងឱឡារិក (ជំហានទីពីរ)
# ភ្នំពេញថ្មី ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩
## សូមស្វាគមន៍នៅក្នុងមហាគ្រួសារនៃព្រះសហគមន៍

**អត្ថបទទី១៖ ទុតិយកថា ២៦,៤-១០**

បូជាចារ្យនឹងទទួលល្អីពីដៃរបស់អ្នក យកទៅតម្កល់នៅមុខអាសនៈព្រះអម្ចាស់ជាព្រះរបស់អ្នក។ ទក ២៦,៤

**អត្ថបទទី២៖ រ៉ូម ១០,៨-១៣**

ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្តអ្នកជឿថា ព្រះជាម្ចាស់ពិតជាបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញមែន នោះអ្នកនឹងទទួលការសង្គ្រោះជាមិនខាន។ រម ១០,៩

**ដំណឹងល្អ៖ លូកា ៤,១-១៣**

ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុងគម្ពីរមានចែងថា មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ»។ លក ៤,៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះពិតមែនជាអំណរសប្បាយសម្រាប់ភូមិភាគភ្នំពេញយើង យើងមានលោកបូជាចារ្យច្រើន ដើម្បីធ្វើដំណើរជាមួយព្រះសហគមន៍ដែលកំពុងស្វាគមន៍បេក្ខជន១៥៤នាក់ ដែលព្រះសហគមន៍បានត្រាស់ហៅយ៉ាងឱឡារិកនៅថ្ងៃនេះ។ យើងឃើញព្រះសហគមន៍របស់យើងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសឆ្នាំនេះយើងមានព្រះសហគមន៍ថ្មីបំផុតដែលមានព្រះសហគមន៍បាទី ព្រះសហគមន៍ត្រពាំងក្រញូង ដែលជាលើកទីមួយមានពិធីជ្រមុជទឹកនៅក្នុងបុណ្យចម្លងខាងមុខ។ នេះជាអំណរសប្បាយរបស់យើង វាជាពេលវេលាមួយពិសេសដោយបងប្អូនដែលអង្គុយនៅទីនេះ ដែលនឹកឃើញប៉ុន្មានឆ្នាំកន្លងមកបានធ្វើដំណើរជាមួយព្រះសហគមន៍ និងរៀងៗខ្លួន មានប្រវត្តិសាស្ត្រផ្ទាល់ខ្លួននៅពេលជួបជាមួយព្រះយេស៊ូ នៅក្នុងព្រះសហគមន៍ដែលបានស្វាគមន៍ ដែលបានលើកទឹកចិត្ត ដែលបានអប់រំ ដែលបានណែនាំនៅតាមភូមិរបស់យើង ដើម្បីរួមជាមួយលោកបូជាចារ្យ រួមជាមួយគ្រូអប់រំជំនឿ រួមជាមួយគ្រីស្តបរិស័ទយើងបានធ្វើដំណើររហូតដល់ថ្ងៃនេះ។ ថ្ងៃនេះសម្រាប់យើងទាំងអស់ ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត ដែលប្រទានផ្លែ ដែលប្រទានជីវិតឲ្យយើងដែលជាព្រះសហគមន៍ដ៏តូចនៅក្នុងប្រទេសកម្ពុជាជាពិសេសភូមិភាគភ្នំពេញ។

សម្រាប់បេក្ខជនទាំង១៥៨នាក់ ដែលបានឲ្យព្រះសហគមន៍ទទួលស្គាល់ថាពួកគេអាចទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរាត្រីបុណ្យចម្លងខាងមុខនេះគឺទីមួយ **សូមពោរពេញដោយមោទនភាព** បន្តិចទៀតយើងទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈ ដោយដឹងថាព្រះជាម្ចាស់បានជ្រើសរើសយើងរៀងៗខ្លួនដើម្បីធ្វើជាកូនបង្កើតរបស់ព្រះជាម្ចាស់ នឹងដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់យើងជានិច្ចដោយគ្មានព្រំដែន។ ហេតុនេះហើយ សូមយើងមានកិត្តិយសនិងមោទនភាព ដោយដឹងថាបន្តិចទៀតយើងកើតជាថ្មីជាមួយព្រះបិតាដែលបានជ្រើសរើស ដើម្បីទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ និងដើម្បីធ្វើដំណើរនៅក្នុងជីវិតតាមរបៀបថ្មី ដោយសារយើងដឹងថាមានព្រះជាម្ចាស់ដែលគង់នៅ មានព្រះជាម្ចាស់មិនលះបង់ចោលយើង មានព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រចំពោះយើងម្នាក់ៗ។

ទីពីរ **សូមស្វាគមន៍នៅក្នុងមហាគ្រួសារនៃព្រះសហគមន៍** ព្រះសហគមន៍ទៅជាមាតារបស់បងប្អូនចាប់ពីពេលនេះតទៅ គឺមានបងប្អូនទាំងអស់ដែលជាបូជាចារ្យ បងប្រុសបងស្រី គ្រីស្តបរិស័ទ គ្រូអប់រំជំនឿ ដែលនៅទីនេះដែលនៅក្នុងភូមិ និងព្រះសហគមន៍ទូទាំងពិភពលោកមានរាប់ពាន់លាននាក់ដែលជាគ្រីស្តបរិស័ទ គឺយើងចូលនៅក្នុងមហាគ្រួសារហ្នឹង។ មុនគេបង្អស់ ព្រះសហគមន៍ដែលជាមាតារបស់យើង តាមភូមិ តាមកន្លែងដែលជាព្រះសហគមន៍កំណើតរបស់យើង ដើម្បីធ្វើដំណើរជាមួយយើង ដើម្បីថែរក្សាយើង សូមស្វាគមន៍ដែលចូលនៅក្នុងមហាគ្រួសារនៃព្រះសហគមន៍របស់ព្រះគ្រីស្ត។

ទីបី **សូមយកចិត្តទុកដាក់ធ្វើជាសាវ័ករបស់ព្រះយេស៊ូ** យើងជាបុត្រាបុត្រីយើងមានមហាគ្រួសារធំមួយ ប៉ុន្តែយើងមានតួនាទី ដោយសារយើងទទួលលក្ខណៈថ្មី យើងទទួលលក្ខខណ្ឌថ្មី យើងទទួលចរិកថ្មីនៅក្នុងជីវិតរបស់យើង សូមធ្វើជាសាវ័ករបស់ព្រះយេស៊ូ មានន័យថាមិត្តសម្លាញ់របស់ព្រះយេស៊ូយ៉ាងជិតស្និត។ មិត្តសម្លាញ់ដែលមានទំនាក់ទំនងជាមួយព្រះយេស៊ូ មិត្តសម្លាញ់ដែលស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ មិត្តសម្លាញ់ដែលអធិដ្ឋានដើម្បីភ្ជាប់ជាមួយព្រះយេស៊ូថែមទៀត និងដើម្បីស្តាប់តើព្រះយេស៊ូទន្ទឹងរង់ចាំអ្វីខ្លះពីខ្ញុំ?

ទីបួន ប៉ុន្តែយើងមិនមែនតែជាសាវ័ក ជាមិត្តសម្លាញ់របស់ព្រះយេស៊ូ លើសពីនេះទៅទៀត **យើងជាគ្រីស្តទូតរបស់ព្រះអង្គ** មានន័យថាទូតរបស់ព្រះយេស៊ូ ដើម្បីប្រកាសដំណឹងល្អតាមសកម្មភាពរបស់យើងនៅក្នុងសេចក្តីពិត។ សព្វថ្ងៃសង្គមរបស់យើងត្រូវការពន្លឺខ្លះ ដើម្បីធ្វើដំណើរទៅមុខបាន ពន្លឺនៃសម្ភារៈនិយម បន្លឺនៃចិត្តលោភលន់ដែលឆាប់រលត់ ផ្ទុយទៅវិញសង្គមរបស់យើងត្រូវការមានពន្លឺមួយដែលមិនអាចរលត់ ជាពន្លឺដែលនៅជាស្ថិតស្ថេរជានិច្ច។ ចាប់ពីពេលនេះតទៅ បងប្អូនទៅជាអំបិល ទៅជាពន្លឺ និងទៅជាមេនៅក្នុងម្សៅនៃសង្គម ដើម្បីឲ្យសង្គម

យើងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងសេចក្ដីស្រឡាញ់ ការអាណិតអាសូរ យកចិត្តទុកដាក់ដល់បងប្អូនឯទៀតៗ ជាពិសេសមនុស្សដែលគេមិនសូវអើពើនៅក្នុងសង្គមបច្ចុប្បន្ននេះ។ កុំខ្លាចក្នុងការធ្វើជាសាក្សីយ៉ាងច្បាស់លាស់ជាក់ស្ដែងអំពីព្រះជន្មរបស់ព្រះយេស៊ូ ដែលគង់នៅជាមួយយើងចាប់ពីពេលនេះតទៅ។ សូមពាក់អាវសជានិច្ច អាវសដែលយើងនឹងទទួលនៅក្នុងរាត្រីបុណ្យចម្លងដែលជាព្រះគ្រីស្តផ្ទាល់ សូមពាក់មួកការពារ ដែលជាការអធិដ្ឋានដើម្បីជាប់ជាមួយព្រះយេស៊ូ សូមពាក់វ៉ែនតា ដែលណែនាំឲ្យយើងចេះលើកលែងទោសដល់បងប្អូនឯទៀតៗ សូមពាក់ស្រោមដៃនៃសេចក្ដីស្រឡាញ់ សូមពាក់ខ្សែក្រវ៉ាត់ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងដើម្បីចេញធ្វើដំណើរសូមពាក់ស្បែកជើងនៃសេចក្តីក្លាហាន នៃសន្តិភាព នៃកម្លាំងកាយកម្លាំងចិត្តដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។

បុត្រាបុត្រីរបស់ព្រះជាម្ចាស់ មហាគ្រួសារនៅក្នុងព្រះសហគមន៍ សាវ័កនិងមិត្តសម្លាញ់របស់ព្រះគ្រីស្ដ គ្រីស្តទូតដែលប្រកាសដំណឹងល្អនិងផ្ដល់សន្តិភាព នេះជាអ្វីដែលបងប្អូននឹងទទួលសម្រាប់មួយជីវិតចាប់ពីពេលនេះតទៅរហូតដល់ថ្ងៃចុងក្រោយនៅលើផែនដីនេះ។

សម្រាប់បងប្អូនដែលជាគ្រីស្តបរិស័ទ ខ្ញុំសូមចែករំលែកពីរចំណុច ដើម្បីឲ្យបងប្អូនធ្វើជាតំណាងព្រះសហគមន៍ ជាព្រះសហគមន៍ដែលកំពុងមានផ្ទៃពោះនិងប្រាំសប្ដាហ៍ទៀតយើងឆ្លងទន្លេ យើងមាន១៥៩នាក់ដែលជាបុត្រាបុត្រីដែលបានកើតចេញពីផ្ទៃរបស់យើង។ ព្រះសហគមន៍ជាម្ដាយ ហេតុនេះហើយលោកឪពុក លោកគ្រូអ្នកគ្រូអប់រំជំនឿ ឪពុកម្ដាយធម៌ និងគ្រីស្តបរស័ទទាំងអស់សូមយកចិត្តទុកដាក់ធ្វើទាំងឪពុក ទាំងម្ដាយ ទាំងបងប្អូនដោយជិតស្និទ្ធជាមួយបងប្អូនដែលសុំទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុខនេះ។ សូមស្រឡាញ់គេ សូមលើកទឹកចិត្តគេ សូមធ្វើដំណើរជាមួយគេ សូមធ្វើជាពន្លឺសម្រាប់គេ ដើម្បីឲ្យគេឃើញព្រះយេស៊ូគ្រីស្តនៅក្នុងយើង។ បន្តិចទៀត យើងមានពិធីជម្រះចិត្តគំនិតទីមួយទីពីរទីបី ដែលជាសញ្ញាសម្គាល់ថាបន្តិចទៀតយើងឆ្លងទន្លេហើយ ចាប់ផ្ដើមឈឺខ្លះៗត្រូវការលាងអំពើបាបភាពងងឹតនៅក្នុងជីវិតរបស់យើង។ សប្ដាហ៍ពិសិដ្ឋដែលព្រះយេស៊ូសោយទិវង្គត ជាពេលវេលាចុងក្រោយដែលយើងឈឺចាប់បំផុតមុនយើងឆ្លងទន្លេនៅយប់បុណ្យចម្លង នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងទឹកដែលលោកឪពុកប្រគល់ជីវិតរបស់ព្រះជាម្ចាស់ដល់១៥៩នាក់ ឲ្យទៅជាបុត្រាបុត្រីយ៉ាងពេញលក្ខណៈរបស់ព្រះជាម្ចាស់ និងសម្រាប់ព្រះសហគមន៍របស់ព្រះគ្រីស្ត។ នេះជាបេសកកម្មរបស់ព្រះសហគមន៍ដែលប្រគល់ឲ្យលោកបូជាចារ្យ ដើម្បីណែនាំឲ្យជីវិតរបស់ព្រះគ្រីស្តចូលទៅក្នុងព្រះសហគមន៍យើងគ្រប់ទីកន្លែង។ ក្នុង៤០ថ្ងៃខាងមុខនេះ ឲ្យយើងជាព្រះសហគមន៍ ទាំងលោកបូជា

ចារ្យ ទាំងបងប្រុសបងស្រី ទាំងគ្រូអប់រំជំនឿ ទាំងឪពុកម្ដាយធម៌ ទាំងគ្រីស្តបរិស័ទទាំងអស់ ធ្វើដំណើរយ៉ាងជិតស្និទ្ធជាមួយ១៥៤នាក់ ដើម្បីទទួលជីវិតដ៏ពេញលក្ខណៈនៅយប់បុណ្យចម្លង។

បងប្អូនជាទីស្រឡាញ់

ពិតមែនសូមអធិដ្ឋាន សូមស្រឡាញ់បងប្អូនទាំង១៥៤នាក់ ឲ្យយើងធ្វើជាព្រះសហគមន៍ដែលស្វាគមន៍បងប្អូនដែលបន្តិចទៀតទទួលអគ្គសញ្ញាជ្រមុជទឹក។ ឲ្យយើងធ្វើជាព្រះសហគមន៍ស្វាគមន៍ដ៏ពេញលក្ខណៈបុត្រាបុត្រីថ្មី ដែលនឹងចូលនៅក្នុងមហាគ្រួសាររបស់យើង។ ឲ្យយើងធ្វើជាព្រះសហគមន៍ដែលបើកទ្វារនៃដួងចិត្ត ដើម្បីស្តាប់លឺសេចក្តីត្រូវការរបស់បងប្អូននៅក្នុងសង្គមបច្ចុប្បន្ននេះ វាជាសក្ខីភាពរបស់យើងដែលជាគ្រីស្តបរិស័ទដែលចេះអធិដ្ឋាន ដែលស្រឡាញ់។ សក្ខីភាពមានតម្លៃ មានឥទ្ធិពលលើសពីធម្មទេសនាទាំងអស់ លើសពីទស្សនៈទាំងអស់ដែលយើងមាន តើសក្ខីភាពរបស់យើងដូចនឹងអ្វីដែលយើងនិយាយពីមួយថ្ងៃទៅមួយថ្ងៃដែរឬទេ? តួនាទីរបស់យើងដែលជាព្រះសហគមន៍ គឺធ្វើជាព្រះគ្រីស្តនៅលើផែនដីនេះ មានន័យថាណែនាំឲ្យអ្នកជំងឺជាសាស្បើយ ណែនាំឲ្យអ្នកក្រីក្រមានម្ហូបអាហារបរិភោគ ណែនាំឲ្យមនុស្សដែលបាត់បង់តម្លៃថ្លៃថ្នូរនៅក្នុងសង្គម មានតម្លៃថ្លៃថ្នូរនៅក្នុងជីវិតរបស់គេដើម្បីរកឃើញសេចក្តីសុខតាមសកម្មភាពរបស់យើង។ យើងអាចព្យាបាល យើងអាចចិញ្ចឹម យើងអាចលើកទឹកចិត្ត ដើម្បីឲ្យមនុស្សទាំងអស់រស់ឡើងវិញជាមួយព្រះយេស៊ូនិងរកឃើញតម្លៃថ្លៃថ្នូរនៃជីវិត។ សកម្មភាពរបស់យើង ស្នាដៃរបស់យើងត្រូវតែពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះគ្រីស្តផ្ទាល់ ឲ្យយើងនឹកឃើញពាក្យប្រស្នារបស់ព្រះយេស៊ូអំពីកូនពៅវង្វេង ដែលមានឪពុកស្វាគមន៍នឹងលើកលែងទោសឲ្យកូន ឲ្យយើងនឹកឃើញពាក្យប្រស្នារបស់ព្រះយេស៊ូអំពីជនសប្បុរសសាសនាសាម៉ារីដែលបានមើលអ្នកត្រូវរបួសតាមផ្លូវ ដោយយកចិត្តព្យាបាល លើកទឹកចិត្ត ធ្វើដំណើរជាមួយគេ។ លើកលែងទោស និងអធិដ្ឋាន ប្រសិនបើព្រះសហគមន៍របស់យើងមិនលើកលែងទោសនិងអធិដ្ឋានយ៉ាងជាក់ស្តែង ប្រសិនបើព្រះសគមន៍របស់យើងគ្មានគ្រីស្តបរិស័ទសកម្ម និងចូលនៅក្នុងស្នាព្រះហស្តរបស់ព្រះជាម្ចាស់ជាប្រចាំ នោះព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដែលចេះតែនិយាយ ប៉ុន្តែអត់មានផ្លែ អត់មានផ្កា អត់មានអ្វីសោះដែលកើតឡើង។

បងប្អូនជាបូជាចារ្យ ជាបងប្រុសបងស្រី ជាគ្រូអប់រំជំនឿ ជាគ្រីស្តបរិស័ទនៅមុខយើង មាន១៥៤នាក់ដែលសុំទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុខនេះ បន្តិចទៀតដោយនាមព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខ្ញុំនឹងត្រាស់ហៅគេ ស្វាគមន៍គេយ៉ាងឱឡារិក។ ព្រះសហគមន៍ធ្លាប់ធ្វើជាម្តាយរបស់គេ ព្រះសហគមន៍ធ្លាប់ធ្វើជាឪពុករបស់គេ ព្រះសហគមន៍ធ្លាប់ធ្វើជាបងប្អូនបង្កើតរបស់គេ ដោយប្រគល់សេចក្តីសង្ឃឹមថ្មីដល់អ្នកជំងឺក្តី ជនពិការក្តី អ្នកអស់

សង្ឃឹមក្តី ចាស់ជរាក្តី កុមារកំព្រាក្តី... ព្រះសហគមន៍របស់យើងនៅតាមភូមិបានឆ្លើយតប និងបានណែនាំឲ្យអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ សូមចិញ្ចឹមគេផ្ទាល់ខ្លួនទៅ ប៉ុន្តែគេបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូដែរ។ មានខ្លះគេបានធ្វើដំណើរជាមួយព្រះសហគមន៍ជាច្រើនឆ្នាំ ដោយសារគេបានជួបព្រះយេស៊ូហើយនៅថ្ងៃនេះគេបានសម្រេចចិត្តលះបង់ចោល ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូដោយលីឈើឆ្កាង។ នឹកឃើញដល់ព្រះគម្ពីរថ្ងៃនេះថា "**មនុស្សមិនរស់ដោយសារអាហារប៉ុណ្ណោះទេ**" គេបានទទួលអាហារមែន បានទទួលសេចក្តីសង្ឃឹមមែន បានទទួលអនាគតល្អមែន ប៉ុន្តែនៅពេលនេះជាពេលវេលាថ្មីដោយដឹងថាជីវិតរបស់យើងអាចទៅមុខដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសារចរិកផ្ទាល់របស់ព្រះអង្គឲ្យយើងទៅជាមនុស្សយ៉ាងពេញលក្ខណៈ និងសេចក្តីសុខសាន្ត។

ព្រឹកនេះយើងមានចំការផ្កាមួយយ៉ាងស្អាតមែនទែន ដែលមានផ្កាឈូកច្រើនណាស់ដែលមានពណ៌ស មានពណ៌ផ្កាឈូក មានពណ៌ក្រហម មានពណ៌លឿង ដែលផ្កាឈូកនេះបានដុះឫសនៅក្នុងភក់នៅក្នុងភាពងងឹតនៅក្នុងទុក្ខលំបាក ប៉ុន្តែនៅពេលនេះបានលូតលាស់បន្តិចម្តងៗ។ ថ្ងៃនេះក្នុងបឹងដែលមានផ្កាឈូកយ៉ាងស្អាតទាំងនេះ បានកំពុងរកឃើញព្រះអាទិត្យគឺព្រះជាម្ចាស់ផ្ទាល់ ដែលរះរហូតដែលណែនាំឲ្យផ្កាឈូកនេះរីកទៅៗ នៅយប់បុណ្យចម្លងផ្កាឈូកនៅតាមព្រះសហគមន៍រីកស្អាតបំផុត ដែលទៅជាផ្កាឈូកដែលរីកអចិន្ត្រៃយ៍ ដែលពោរពេញដោយពន្លឺរបស់ព្រះជាម្ចាស់ ដោយយើងដឹងថាព្រះអាទិត្យរបស់ព្រះជាម្ចាស់បេះមិនបាន។

ព្រឹកនេះ យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា "**ក្នុងគម្ពីរមានចែងថាអ្នកត្រូវតែថ្វាយបង្គំព្រះជាម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ**" នេះជាមូលហេតុយើងមានព្រះតែមួយអង្គ យើងបម្រើព្រះជាម្ចាស់តែមួយគឺព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត ដែលបានស្រឡាញ់យើងនិងកំពុងធ្វើដំណើរជាមួយយើង។ ព្រះសហគមន៍ភូមិភាគភ្នំពេញអើយ សូមពោរពេញដោយមោទនភាព ដោយសារយើងបានទទួលបេសកកម្មគឺប្រកាសដំណឹងល្អ ឲ្យយើងយកចិត្តទុកដាក់ បំពេញបេសកកម្មដែលយើងបានទទួលពីព្រះជាម្ចាស់។ សូមអធិដ្ឋានដល់ព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍របស់យើង ថែរក្សាយើងទាំងអស់គ្នានៅក្នុងសេចក្តីសុខសាន្តរបស់ព្រះអង្គ ដើម្បីឲ្យយើងរស់នៅនៅក្នុងព្រះបិតា នៅក្នុងព្រះយេស៊ូគ្រីស្ត និងនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយយកចិត្តទុកដាក់ផ្តល់សក្ខីភាពអស់ពីកម្លាំងកាយកម្លាំងចិត្តអំពីសេចក្តីស្រឡាញ់ ដែលឈ្នះជានិច្ចនៅក្នុងដួងចិត្តរបស់យើង និងដែលជម្រុញយើងឲ្យយើងទៅប្រកាសដំណឹងល្អតទៅទៀត ដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះអង្គទៅគ្រប់ទីកន្លែងនៅក្នុងសង្គមបច្ចុប្បន្ននេះ។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយទូលអង្វរព្រះអង្គសូមព្រះវិញ្ញាណដ៏

វិសុទ្ធយាងមក  ដើម្បីបំភ្លឺព្រះសហគមន៍យើង  បំភ្លឺយើងរៀងៗខ្លួន  ឲ្យព្រះសហគមន៍របស់យើង ទៅជាគ្រួសារដ៏សុខសាន្ត ដោយសារជាគ្រួសាររបស់ព្រះជាម្ចាស់។ អាម៉ែន៕